# ព្រះរាជក្រឹត្យ

នស/រកត/០១០៦/០៤៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
## សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បង្កើតគណៈកម្មាធិការជាតិជំរុញចលនា " ភូមិមួយ ផលិតផលមួយ " ហៅកាត់ថា "គ១.ផ១"
ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- សម្តេច | **ហ៊ុន សែន** | ប្រធាន |
| ២- ឯកឧត្តម | **សុខ អាន** | អនុប្រធាន |
| ៣- ឯកឧត្តម | **សុន គន្ធរ** | អគ្គលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |

Downloaded from http://www.khmerlaws.com

**មាត្រា ២** : តួនាទី ភារកិច្ចនៃ "គ១.៨១" សមាសភាពសមាជិក ដែលជាតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអគ្គលេខាធិការរង មន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន រួមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន "គ១.៨១" នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣** : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស-០៦០១-០៤៨

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០០៦*

លេខៈ ៥៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណារិន្ទ តាន់**

Downloaded from http://www.khmerlaws.com